ឯកសារសិក្សាគោលនយោបាយសង្ខេប
ការចេញផ្សាយលេខ ០១ ឆ្នាំ២០១៨
ការបោះពុម្ពផ្សាយរបស់ ក្រុមប្រឹក្សាស្រាវជ្រាវអប់រំ
ក + ខ - គ × ឃ ÷ Л ∑ ψ ∫ ϕ Ω ៛ $ ☺
ការបោះផ្សាយនេះឧបត្ថម្ភដោយគម្រោងហិរញ្ញវត្ថុធនាគារអភិវឌ្ឍន៍អាស៊ី 2427 CAM (COL)

# តើកម្មវិធីសិក្សានៅកម្ពុជាជួយសិស្សឱ្យត្រៀមខ្លួនបានដល់កម្រិតណាសម្រាប់បរិបទសេដ្ឋកិច្ចពុទ្ធិ?

ដោយ ងិន ច័ន្ទរិទ្ធ
សាកលវិទ្យាល័យភូមិន្ទភ្នំពេញ ប្រទេសកម្ពុជា និង សាកលវិទ្យាល័យអ៊ុកលែន ប្រទេសនូវែលហ្សេឡង់

សារគន្លឹះ

- ប្រទេសកម្ពុជាត្រូវធ្វើវិសិដ្ឋកម្មកម្លាំងពលកម្មនាពេលបច្ចុប្បន្នរបស់ខ្លួនដែលពឹងផ្អែកជាចំបងលើកម្លាំងកាយ និងជំនាញតិចតួចទៅកម្លាំងពលកម្មនវានុវត្តន៍ និងមានជំនាញកម្រិតខ្ពស់ ប្រសិនបើចង់ឈានទៅសម្រេចជោគជ័យនូវចក្ខុវិស័យសេដ្ឋកិច្ចពុទ្ធិ។
- គោលនយោបាយកម្មវិធីសិក្សាទូទៅ ផ្តោតសំខាន់លើការសិក្សាបែប "សិស្សមជ្ឈមណ្ឌល" ឬការសិក្សាតាមវិធីរិះរក ក្នុងគោលបំណងផលិតកម្លាំងពលកម្មដែលមានភាពបត់បែន និងភាពច្នៃប្រឌិតខ្ពស់ ប្រកបដោយជំនាញសញ្ញាណកម្មកម្រិតខ្ពស់ ដែលជាលក្ខខណ្ឌចាំបាច់សម្រាប់សេដ្ឋកិច្ចពុទ្ធិ។
- ផ្ទុយទៅវិញ សៀវភៅសិក្សាសម្រាប់កម្រិតមធ្យមសិក្សាទុតិយភូមិ សង្កត់ធ្ងន់ជាសំខាន់លើខ្លឹមសារ និងសកម្មភាពសិក្សាដែលមានជំនាញសញ្ញាណកម្មកម្រិតទាបនៅឡើយ។
- ការណ៍នេះ ទាមទារឱ្យមានការកែតម្រូវសៀវភៅសិក្សា ឬការប្រើប្រាស់សម្ភារៈសិក្សាបន្ថែម ដើម្បីពង្រឹងធាតុសិក្សាសកម្មសម្រាប់ផលិតកម្លាំងពលកម្មដែលត្រូវការ ដើម្បីឈានទៅសម្រេចបាននូវចក្ខុវិស័យខាងលើ។

## សេចក្តីផ្តើម

ប្រព័ន្ធអប់រំកម្ពុជាមានគោលដៅអភិវឌ្ឍធនធានមនុស្សសម្រាប់សេដ្ឋកិច្ចពុទ្ធិ (អ.យ.ក, ២០១៤)។ ចក្ខុវិស័យនេះ ស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មឆ្នាំ ២០១៥-២០១៥ ដែលមានគោលបំណង កែប្រែកម្ពុជាពីប្រទេសមានចំណូលមធ្យមកម្រិតទាបទៅជាប្រទេសមានចំណូលកម្រិតមធ្យមកម្រិតខ្ពស់ត្រឹមឆ្នាំ ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅត្រឹមឆ្នាំ២០៥០ ( រាជរដ្ឋាភិបាលកម្ពុជា (រា.រ.ក), ២០១៣, ២០១៥)។ ដើម្បីសម្រេចគោលដៅនេះ ប្រទេសកម្ពុជាចាំបាច់ត្រូវធ្វើវិសិដ្ឋកម្មធនធានមនុស្សពីកម្លាំងពលកម្មបច្ចុប្បន្នដែលពឹងផ្អែកជាចំបងលើកម្លាំងកាយ និងជំនាញតិចតួចទៅកម្លាំងពលកម្មនវានុវត្តន៍ និងមានមានជំនាញកម្រិតខ្ពស់។ ដូច្នេះ តើប្រព័ន្ធអប់រំយើងត្រៀមខ្លួនរួចរាល់បានកម្រិតណាដើម្បីសម្រេចការងារនេះ? ឯកសារសិក្សាគោលនយោបាយសង្ខេបនេះ បង្ហាញពីរបកគំហើញសំខាន់ៗនៃវិវេចនាសៀវភៅសិក្សាកម្រិតមធ្យមសិក្សាទុតិយភូមិ[1] (ជេត និងអ្ន.ផ, ២០១៤) ដែលបានសិក្សាវែកញែកពីទំនាក់ទំនងរវាងខ្លឹម

[1] វិធីសាស្ត្រស្រាវជ្រាវដែលយើងប្រើក្នុងការសិក្សានេះ គឺការធ្វើវិវេចនាសៀវភៅសិក្សាមួយជំពូកម្តងៗ ដោយសាស្ត្រាចារ្យដែលមានជំនាញច្បាស់លាស់លើមុខវិជ្ជាដែលបានធ្វើវិវេចនានោះ។ វិវេចនា ផ្តោតលើចំណេះដឹង បំណិន និងផលប៉ះពាល់ដល់ឥរិយាបថសិស្ស តាមខ្លឹមសារមេរៀននៃមុខវិជ្ជានីមួយៗ ដោយផ្អែកលើវិជ្ជានុក្រមប្លូម (អែនឌឺរ៍សឺន និងខ្រាថវ៉ូហ្ល៍, Anderson and Krathwohl, ២០០១)។ មុខវិជ្ជាដែលយកមកស្រាវជ្រាវនេះ រួមមាន គណិតវិទ្យា ភាសាខ្មែរ រូបវិទ្យា គីមីវិទ្យា និងជីវវិទ្យា សម្រាប់ថ្នាក់ទី ០៩ និងទី ១២។

សារនៃកម្មវិធីអប់រំក្នុងសៀវភៅសិក្សា គោលនយោបាយកម្មវិធីសិក្សាជាតិ និងលក្ខណៈសម្បត្តិនៃកម្លាំងពលកម្មសម្រាប់សេដ្ឋកិច្ចពុទ្ធិ និងស្នើគំនិតសម្រាប់យកទៅអនុវត្តក្នុងគោលនយោបាយពាក់ព័ន្ធ។

## តើសេដ្ឋកិច្ចកម្ពុជាធ្វើដំណើរឆ្ពោះទៅទីណា?

សេដ្ឋកិច្ចកម្ពុជា មានកំណើនយ៉ាងខ្លាំងក្នុងប៉ុន្មានទសវត្សចុងក្រោយនេះ។ អត្រាកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំជាមធ្យមគឺ ៧,៨ភាគរយ ក្នុងអំឡុងពីឆ្នាំ ១៩៩៧ ដល់ឆ្នាំ២០១៤ ដោយមានអត្រាកំណើនចុងក្រោយគឺ ៦,៨ ភាគរយនៅឆ្នាំ ២០១៧ (ធនាគារពិភពលោក, ២០១៨)។ ផលិតផលក្នុងស្រុកសរុប (ផ.ផ.ស)សម្រាប់មនុស្សម្នាក់ៗកើនឡើងពី ២១៦ ដុល្លារ នៅឆ្នាំ១៩៩២ ដល់ ១ ៣៧៥ ដុល្លារ នៅឆ្នាំ២០១៧ (ធនាគារពិភពលោក, ២០១៨)។ ប្រភពនៃកំណើនសេដ្ឋកិច្ច ពឹងផ្អែកតិចតួចលើវិស័យកសិកម្ម (២៣,៣៨ ភាគរយនៃ ផ.ផ.ស) នៅឆ្នាំ២០១៧ តែពឹងផ្អែកខ្លាំងលើវិស័យឧស្សាហកម្ម (៣០,៨៨ភាគរយ) និងវិស័យសេវាកម្ម (៣៩,៦៧ភាគរយ) (ធនាគារពិភពលោក, ២០១៨)។ ជាពិសេស កសិឧស្សាហកម្ម ទេសចរណ៍ សំណង់ និងវាយនភណ្ឌ ជាវិស័យដ៏សំខាន់ក្នុងការជំរុញកំណើនសេដ្ឋកិច្ច។ ថ្មីៗនេះ កម្ពុជាបានធ្វើពិពិធកម្មប្រភពសេដ្ឋកិច្ចរបស់ខ្លួន ហើយបានឈានដល់ការបង្កើតផលិតកម្មធុនធ្ងន់ ដោយបង្កើនការនាំចេញគ្រឿងម៉ាស៊ីនអេឡិចត្រូនិក ឧបករណ៍ និងគ្រឿងបន្លាស់យានយន្ត។ នេះជាការចាប់ផ្តើមនៃឧស្សាហកម្មធុនស្រាល (ជាពិសេសការដំឡើង និងផលិតគ្រឿងអេឡិចត្រូនិក) ដែលត្រូវការកម្លាំងពលកម្មដែលមានជំនាញកម្រិតមធ្យម។

ដើម្បីក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ត្រឹមឆ្នាំ២០៣០ កម្ពុជាចាំបាច់ត្រូវរក្សាកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំចំនួន ៧ភាគរយ ហើយត្រូវអភិវឌ្ឍខ្លួនទៅជាប្រទេសដែលមានសេដ្ឋកិច្ចឧស្សាហកម្ម (រ.រ.ក, ២០១៥)។ មហិច្ឆតានេះសម្រេចបាន ត្រូវការកម្លាំងពលកម្មជំនាញនវានុវត្តន៍ មានផលិតភាពខ្ពស់ និងអាចស្រូបយកបច្ចេកវិទ្យាថ្មីៗ ដើម្បីអាចតាមទាន់ការផ្លាស់ប្តូរបរិបទនានាក្នុងប្រព័ន្ធសេដ្ឋកិច្ច។ កំណើនសេដ្ឋកិច្ចកម្ពុជា កំពុងតែស្រេកឃ្លានការផ្គត់ផ្គង់ការងារប្រពលវិជ្ជា ដែលទាមទារភាពច្នៃប្រឌិត ភាពជាអ្នកដឹកនាំ បំណិនប្រសប់ក្នុងការដោះស្រាយបញ្ហា ភាសា និងជំនាញបច្ចេកវិទ្យាដែលសាំញ៉ាំជាងមុន (ធនាគារពិភពលោក, ២០១៨)។ ជាពិសេស ជំនាញដែលទាមទារដោយការងារថ្មីៗនាពេលបច្ចុប្បន្នរួមមាន៖ "បំណិនសញ្ញាណកម្មលំដាប់ខ្ពស់៖ ជំនាញប្រាស្រ័យទាក់ទងផ្ទាល់មាត់ ភាសាបរទេស។ បំណិនអាកប្បកិរិយាសង្គម៖ សេវាកម្មអតិថិជន ការងារជាក្រុម ការបង្កើតគំនិតផ្តួចផ្តើម។ អក្ខរកម្មឌីជីថល៖ ចំណេះដឹងខាងព័ត៌មានវិទ្យា ការសម្របខ្លួនទៅនឹងឧបករណ៍ និងប្រតិបត្តិការថ្មីៗ ព្រមទាំងជំនាញប្រពៃណី តម្រឹកដៃក្នុងការសម្តែងសិល្បៈនានា" (ធនាគារពិភពលោក, ទំ.៤៩, ២០១៨)។

គន្លងដំណើរនេះ ស្របជាមួយនឹងបទពិសោធន៍អាស៊ីដែលបង្ហាញថា កម្លាំងពលកម្មរបស់ប្រទេសដែលមានសេដ្ឋកិច្ចចំណូលមធ្យមកម្រិតខ្ពស់ ដែលបានរួចផុតពី "អន្ទាក់នៃចំណូលមធ្យម" ទៅបាន ដោយសារតែកម្លាំងពលកម្មរបស់គេ សុទ្ធតែមានចំណេះដឹង ជំនាញ និងឥរិយាបថប្រកបដោយ "សញ្ញាណកម្មលំដាប់ខ្ពស់" ដែលសុទ្ធតែអាចត្រូវបានបណ្តុះបណ្តាលឱ្យត្រូវចំតាមតម្រូវការវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាដែលជាលក្ខខណ្ឌចាំបាច់សម្រាប់សេដ្ឋកិច្ចពុទ្ធិនោះ (វិលសុន, ២០១៤; វ៉ាន់និងម៉ារហ្គេន, ២០១៧; យូស៊ីណូ និងអ្ន.ផ, ២០១៨)។ ដើម្បីបានធនធានមនុស្សដ៏ខ្លាំងបែបនេះ កម្មវិធីសិក្សាអប់រំត្រូវកសាងយ៉ាងហោចណាស់ឱ្យបានមូលដ្ឋានគ្រឹះមួយសម្រាប់អ្នកសិក្សាបែបសកម្ម និងកម្លាំងពលកម្មប្រើការកើតតាមទាន់សភាពការណ៍។

**តើកម្មវិធីសិក្សាត្រូវនឹងគោលបំណងដូចនេះឬទេ?**

ប្រទេសកម្ពុជា បានឆ្លងកាត់នូវកំណែទម្រង់កម្មវិធីសិក្សាអប់រំទូទៅ៥ដងរួចមកហើយជាការឆ្លើយតបនឹងយុទ្ធសាស្ត្រអភិវឌ្ឍការអប់រំ និងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម (អ.យ.ក, ២០១៥)។ ប្រវត្តិកាលសំខាន់នៃកំណែទម្រង់គឺ ១៩៨០-១៩៨៧, ១៩៨៧-១៩៩៦, ១៩៩៦-២០០៥, ២០០៥-២០០៩, និង ២០១៥-បច្ចុប្បន្ន។ ចំណុចប្រសព្វដ៏សំខាន់នៃកំណែប្រែកម្មវិធីសិក្សាគឺនៅឆ្នាំ១៩៩៦ ពេលដែលកម្មវិធីសិក្សាឆ្នាំ ១៩៩៦-២០០៥ត្រូវបានហៅថា វិធីសាស្ត្របង្រៀន និងសិក្សាបែប "សិស្សជាមជ្ឈមណ្ឌល" (អ.យ.ក, ១៩៩៦)។ ហេតុការណ៍នេះបណ្តាលឱ្យមានការសរសេរសៀវភៅសិក្សា និងសៀវភៅឧបទេសគ្រូឡើងវិញដើម្បីឆ្លើយតបនឹងគរុកោសល្យថ្មី។

វិធីសាស្ត្រសិស្សមជ្ឈមណ្ឌលគឺផ្តោតទៅលើ"សកម្មភាពសិស្ស" សិស្សគឺជា"អ្នកចូលរួមសកម្ម" នៅក្នុងដំណើរការសិក្សាឯករាជ្យជាបុគ្គលឬនៅក្នុងក្រុមឬនៅក្រៅថ្នាក់រៀន ហើយគ្រូធ្វើជា "អ្នកសម្របសម្រួលឬជាអ្នកជំរុញ" (អ.យ.ក, ទំ.១៨, ២០០១)។ គេមានគោលបំណងជំរុញសិស្សឱ្យ "យល់ច្បាស់ពីបរិស្ថានជុំវិញខ្លួន អនុវត្តវិធីសាស្ត្រដោះស្រាយបញ្ហា ហើយធ្វើសិស្សកាន់តែមានស្មារតីនាវានុវត្តន៍" (ណាត, ទំ.១៦, ១៩៩៩)។ ការចូលរួមដ៏សកម្មរបស់សិស្សក្នុងសកម្មភាពសិក្សានិងការគិតពិចារណាកម្រិតខ្ពស់ត្រូវបានបង្ហាញនៅក្នុងកម្មវិធីសិក្សានិងគោលនយោបាយអប់រំបន្តបន្ទាប់។ ជាឧទាហរណ៍ គោលនយោបាយសាលាមេត្រី ឆ្នាំ២០១៧ បានពង្រឹងការអប់រំបែបសិស្សមជ្ឈមណ្ឌលដែលផ្តោតលើការចូលរួម និងកិច្ចសហប្រតិបត្តិការ ការដោះស្រាយបញ្ហា ការស្រាវជ្រាវ ការវិភាគ និងសមត្ថភាពពិចារណារកហេតុផលរបស់សិស្ស (អ.យ.ក, ២០០៧)។ គោលនយោបាយនិងសេចក្តីណែនាំឆ្នាំ ២០១២ ស្តីពីការអភិវឌ្ឍសៀវភៅសិក្សាគោលបានពន្យល់ថា "គេសរសេរសៀវភៅសិក្សាឡើងដើម្បីលើកកម្ពស់ជំនាញត្រិះរិះពិចារណាកម្រិតខ្ពស់របស់សិស្សដូចជាការវិភាគ ការអនុវត្ត សំយោគ និងការវាយតម្លៃ" (អ.យ.ក, ទំ.២៧, ២០១២)។ និយាយជារួម កម្មវិធីសិក្សាអប់រំទូទៅមានគោលបំណងឱ្យសិស្សចេះប្រើសក្តានុពលរបស់ខ្លួន និងបណ្តុះបណ្តាលសិស្សឱ្យមានភាពជាពលរដ្ឋ "ពេញលេញ"។ នេះជាភស្តុតាងនៅក្នុងគោលនយោបាយសម្រាប់ការអភិវឌ្ឍកម្មវិធីអប់រំ ឆ្នាំ២០០៥-២០០៩ ដែលមានគោលបំណង "អភិវឌ្ឍយ៉ាងពេញលេញនូវទេពកោសល្យនិងសមត្ថភាពរបស់សិស្សទាំងអស់ដើម្បី ឱ្យសិស្សអាចក្លាយជាមនុស្សមានសមត្ថភាពអមជាមួយ បញ្ញា ស្មារតី សតិដែលមានតុល្យភាព និងស្របទិសដៅគ្នា រួមទាំងការអភិវឌ្ឍនិងការលូតលាស់ខាងរាងកាយ" (អ.យ.ក, ទំ.៤, ២០០៤)។ ទន្ទឹមនឹងនេះ ក្របខណ្ឌកម្មវិធីសិក្សាសម្រាប់ការអប់រំចំណេះទូទៅ និងបច្ចេកទេសបច្ចុប្បន្ន រៀបរៀងឡើង "ដើម្បីធានាថាពលរដ្ឋទាំងអស់អាចអភិវឌ្ឍនូវសក្តានុពលពេញលេញ និងមានភាពរីកចម្រើនអមជាមួយនឹងរូបរាងកាយ ចំណេះដឹង និង អាកប្បកិរិយាដែលមានសមតុល្យនឹងគ្នា" សម្រាប់ការអភិវឌ្ឍជាតិ(អ.យ.ក, ទំ.២, ២០១៥)។

និយាយម្យ៉ាងទៀត គោលនយោបាយកម្មវិធីសិក្សាថ្នាក់ជាតិមានគោលបំណងកសាងអ្នកសិក្សាសកម្មនិងកម្លាំងពលកម្មដែលបត់បែនតាមរយៈការអប់រំដែលផ្តោតសំខាន់លើការចេះសាកសួរដេញដោល។ ប្រេន និងអូប៊ើក Branch and Oberg (ទំ.១, ២០០៤) កំណត់ការសិក្សាតាមបែបរិះរកថាជា "ដំណើរការដែលសិស្សចូលរួមការសិក្សា បង្កើតសំណួរ និងស៊ើបអង្កេតយ៉ាងទូលំទូលាយ ហើយបន្ទាប់មកបង្កើតការយល់ដឹង ចេះទាញន័យ និងចំណេះដឹងថ្មី"។ ការណ៍នេះ គឺស្រប

ជាមួយនឹងវិធីសាស្ត្រសិស្សមជ្ឈមណ្ឌលដែលអនុវត្តដោយប្រព័ន្ធអប់រំ។ ប៉ុន្តែ ស្របពេលដែលវិធីសាស្ត្របង្រៀនមើលទៅមានភាពពេញលេញ ខ្លឹមសារកម្មវិធីសិក្សាតម្រង់ទិសសិស្សទៅកាន់ការសិក្សាបែបនេះ។ ទោះបីជាយ៉ាងណាក៏ដោយ វិវេចនាសៀវភៅសិក្សា (ជេត Chet និងអ្នក.ផ, ២០១៤) មិនបានបង្ហាញពីលក្ខណៈពិសេសដែលជំរុញឱ្យមានអ្នកសិក្សាសកម្មនិងមានភាពច្នៃប្រឌិត ដែលប្រកបដោយចំណេះដឹង ជំនាញនិងឥរិយាបថថ្នាក់សញ្ញាណកម្មកម្រិតខ្ពស់។ ការណ៍នេះផ្ទុយនឹងបញ្ញត្តិនៃគោលនយោបាយកម្មវិធីសិក្សាជាតិនិងតម្រូវការនៃសេដ្ឋកិច្ចពុទ្ធិ។

**ចំណេះដឹងរាក់ និងមិនគ្រប់ជ្រុងជ្រោយ បង្អាក់ការរៀនសូត្របែបសកម្ម និងមានប្រយោជន៍**

លទ្ធផលនៃការវិភាគសៀវភៅសិក្សាបង្ហាញថា ខ្លឹមសារមេរៀនសម្រាប់សិស្សរៀនមានភាពស្មុគស្មាញ ចោះៗ និងមិនមានការពន្យល់ក្បោះក្បាយ។ ការណ៍នេះកើតឡើងដោយសារតែលំដាប់នៃភាពលំបាកក្នុងខ្លឹមសារមេរៀនមានអសង្គតិភាព (តាមពិតគួរតែរៀបពីលំដាប់មូលដ្ឋានទៅលំដាប់ខ្ពស់ជាង)។ មួយវិញទៀត គោលគំនិតនៃមេរៀនមិនបានរៀបចំឱ្យមានលំដាប់លំដោយលំហូរត្រឹមត្រូវនោះទេ។ ហេតុនេះ ចំណុចធ្វើឱ្យសិស្សមានការលំបាកនឹងចាប់យកគោលគំនិត និងបង្កើនចំណេះដឹងឱ្យបានច្រើននិងស៊ីសង្វាក់គ្នា។

មានព័ត៌មានពិតជាក់ស្តែងយ៉ាងច្រើន ដែលសរសេរបែបជាទ្រឹស្តីជាជាងបែបអនុវត្ត។ ការពិពណ៌នា និងពន្យល់សេចក្តីអំពីព័ត៌មានពិតទាំងនោះ ខ្វះឧទាហរណ៍ជាក់ស្តែងដើម្បីផ្ទុះបញ្ចាំង និងផ្តល់អំណះអំណាងគាំទ្រព័ត៌មាន ឬគោលគំនិតទាំងនោះ។ អ្វីដែលគួរឱ្យបារម្ភលើសពីនេះទៅទៀតនោះ គឺភាពមិនជាប់ទាក់ទងគ្នាក្នុងមុខវិជ្ជាវិទ្យាសាស្ត្រ។ ខ្លឹមសារ និងវិធីសាស្ត្រមេរៀនវិទ្យាសាស្ត្រ នៅមានភាពដាច់ពីគ្នាពីមុខវិជ្ជាមួយទៅមុខវិជ្ជាមួយទៀត និងមិនបានច្របាច់បញ្ចូលគ្នាឱ្យបានត្រឹមត្រូវដូចដែលធ្លាប់ធ្វើកន្លងមកនោះទេ។ ឧទាហរណ៍ជាច្រើន មិនអាចប្រើការកើត មានន័យថា វាមិនជាក់ស្តែងដូចសិស្សធ្លាប់ជួបប្រទះក្នុងជីវិតប្រចាំថ្ងៃ។ ជាទូទៅ មេរៀនដែលយកមកបង្រៀន ទាញចេញពីទ្រឹស្តី ទាញចេញពីការពិសោធសមស្របសម្រាប់ប្រើក្នុងមន្ទីរពិសោធន៍ តែវាមានការលំបាកឱ្យសិស្សតភ្ជាប់ទ្រឹស្តីទាំងនោះជាមួយហេតុការណ៍ពិតៗកើតឡើងក្នុងជីវិត។ ចំណុចចុងក្រោយ ខ្លឹមសារមេរៀននីមួយៗមិនគ្រប់គ្រាន់សម្រាប់ថ្នាក់មួយៗ។ បើប្រៀបធៀបជាមួយនឹងសៀវភៅសិក្សាកម្រិតដូចគ្នារបស់ប្រទេសរីកចម្រើនដទៃ ដូចជាប្រទេសសិង្ហបុរីជាដើម (អ.យ.ក, ២០០៦, ២០០៨, ២០១៣) ខ្លឹមសារមេរៀននៅមានមិនទាន់មានវិត្ថារភាព និងគម្ភីរភាព។ ការណ៍នេះ នឹងបង្អាក់មិនឱ្យសិស្សកសាងបាននូវមូលដ្ឋានគ្រឹះសម្រាប់បង្កើនសញ្ញាណកម្មខ្ពស់បានឡើយ។

**ទម្រង់មេរៀនបែបទន្ទេញចាំមាត់ ធ្វើឱ្យមានបំណិនគិតលំដាប់ទាប**

ខ្លឹមសារមេរៀនច្រើនណាស់ ដែលផ្តោតសំខាន់លើការចងចាំ ការយល់ដឹង និងការអនុវត្តចំណេះដឹងពីតថភាព។ ក្នុងការប្រើវិធីនេះ ជួនកាលយើងប្រើសំណួរ "របៀបណា" និង "ហេតុអ្វី" ខ្លះដែរ ក៏ប៉ុន្តែអ្នកសិក្សានៅតែរៀនតាមបែបទន្ទេញឱ្យចាំ និងឆ្លើយសំណួរតាមតែគេដាក់ឱ្យពីអត្ថបទហើយស្រេច ពោលគឺមិនបានឆ្លើយតាមការយល់ដឹងដោយខ្លួនឯងឡើយ។ ទង្វើនេះនឹង ១) មិនលើកទឹកចិត្តសិស្សឱ្យ "គិតចេញផុតពីប្រអប់គំនិត" ២) មានរបកគំនិតប្លែកៗ ៣) ចេះធ្វើនយកម្ម (ឱ្យន័យ) ដោយខ្លួនឯង ៤) ហ៊ានអះអាងការពិសោធឃើញរបស់ខ្លួន និង ៥) ចេះប្រើសក្តានុភាពរបស់ខ្លួន។

មេរៀនវិទ្យាសាស្ត្រជាច្រើន មិនបានបង្ហាញអំពីអភិក្រមវិទ្យាសាស្ត្រឱ្យបានគ្រប់ជ្រុងជ្រោយ និងភាពប្រទាក់ក្រឡាគ្នា ដូចដែលបានលើកឡើងខាងលើនោះទេ ពោលគឺពុំមានឆ្លងកាត់ការពិសោធក្នុងពិភពការងារជាក់ស្តែងឱ្យបានគ្រប់គ្រាន់។ ជាទូទៅ ការធ្វើពិសោធន៍មានលំដាប់លំដោយនីតិវិធីច្បាស់លាស់ ដែលទាមទារការចងចាំខ្ពស់ និងការអនុវត្តឱ្យបានត្រឹមត្រូវ គឺថា វាកម្រនឹងមានចន្លោះប្រហោងសម្រាប់ភាពបត់បែន និងភាពកែច្នៃក្នុងគោលគំនិត និងការធ្វើពិសោធន៍ណាស់។

ជាទូទៅ បំណិនគិតលំដាប់ខ្ពស់ មិនឃើញមានក្នុងលំហាត់ណាដែលពាក់ព័ន្ធនឹងមេរៀនធ្វើពុទ្ធិ និងវិចារណកម្មសំខាន់ៗ។ ធាតុស្នូលនៃការអនុវត្តវិជ្ជានុក្រមប្លុំម (Bloom‟s Taxonomy) (ការប្រើប្រាស់ព័ត៌មានក្នុងស្ថានភាពមួយថ្មី) ការវិភាគ (សំយោគគំនិត) វង្វាយតម្លៃ (ឱ្យហេតុផលជំហរគំនិត ឬការសម្រេចចិត្ត) និងការបង្កើតអ្វីមួយ (ការផលិតថ្មី ឬចេញពីស្នាដៃដើម) (អែនឌឺរ៍សឺន និងខ្រាថវ៉ូហ្ល៍, Anderson and Krathwohl, ២០០១) គឺថាស្ទើរតែមិនមានសោះតែម្តង។ របៀបរៀន និងការអនុវត្តបែបការចងចាំជាធំបែបនោះ នឹងធ្វើឱ្យសិស្សកាន់ជាប់ក្នុងរបៀបគិតរាក់ៗថែមទៀត។

កង្វះខាតការគិតមានហេតុផលនិងការរៀនដែលប្រើការបានរារាំងមិនឱ្យមានឥរិយាបថវិជ្ជមានចំពោះការសិក្សា

តើការសិក្សាតាមតែទម្លាប់ដដែលៗគ្មានភាពអនុវត្តបាន មានទំនាក់ទំនងយ៉ាងណាខ្លះទៅនឹងឥរិយាបថរបស់សិស្ស? ដំបូង ការរៀនបែបទន្ទេញចាំដោយមិនយល់ដឹង នឹងបង្កើតបានអ្នករៀនបែបអសកម្ម គឺថាជាមនុស្សដែលស្ពឹកទម្រន់ក្នុងការស្វែងរកចំណេះដឹងថ្មីៗ។ ទីពីរ ការបង្រៀនអំពីការពិត ដោយគ្មានការពន្យល់ត្រឹមត្រូវ ឬដោយគ្មានសនិទានកម្មសមស្រប នឹងបំផ្លាញសមត្ថភាពគិតមានហេតុផលរបស់សិស្ស។ ទីបី គម្លាតឆ្ងាយរវាងមេរៀននៅសាលានិងជីវិតពិតប្រចាំថ្ងៃ នឹងបង្កើតទស្សនាទានមួយថា ចំណេះដឹងដែលទទួលបានពីសាលារៀន ប្រើការមិនកើត និងមិនសំខាន់។ រូបភាពនេះ នឹងរារាំងសិស្សមិនឱ្យប្រើចំណេះដឹងដែលមានប្រយោជន៍ក្នុងសកម្មភាពរស់នៅប្រចាំថ្ងៃ។ ជាងចុងក្រោយ សិស្សដែលពុំមានការលើកទឹកចិត្តឱ្យចេះសួរ និងគិតពិចារណាដោយខ្លួនឯង នឹងលែងមានចំណាប់អារម្មណ៍ក្នុងការសិក្សា។ ផលប៉ះពាល់ដែលគួរឱ្យបារម្ភជាងនេះទៀតនោះ គឺថាសិស្សដែលមានគំនិតអសកម្មភាពនេះ នឹងមានឥរិយាបថអវិជ្ជមានចំពោះការសិក្សា ទាំងពេលបច្ចុប្បន្ន និងពេលក្រោយណាមួយទៀតក្នុងឆាកជីវិត គឺថាមិនចេះរៀនសូត្រពេញមួយជីវិតខ្លួនបានឡើយ។

## សេចក្តីសន្និដ្ឋាន និងគោលនយោបាយពាក់ព័ន្ធ

មាគ៌ាទៅកាន់សេដ្ឋកិច្ចពុទ្ធិដ៏ទំនើបមួយ (សម្រាប់អនាគតកម្ពុជា) ទាមទារឱ្យមានបំផ្លាស់ប្តូរកម្មវិធីអប់រំឱ្យបានស៊ីជម្រៅ ដើម្បីផលិតកម្លាំងពលកម្មនវានុវត្តន៍ និងមានជំនាញខ្ពស់។ ឯកសារសិក្សាគោលនយោបាយសង្ខេបនេះ លើកឡើងអំពីចំណុចខ្សោយរបស់កម្មវិធីអប់រំដែលយើងបានប្រើសម្រាប់ការអប់រំកម្រិតមធ្យមសិក្សាទុតិយភូមិ ដែលជាមូលដ្ឋានគ្រឹះសម្រាប់ធនធានមនុស្សដែលយើងចង់បានសម្រាប់ក្តីសុបិនសេដ្ឋកិច្ចពុទ្ធិរបស់យើងនោះ។ សៀវភៅសិក្សា ដែលជាធាតុស្នូលនៃកម្មវិធីអប់រំនោះ មិនមានខ្លឹមសារមេរៀនបែបស្វ័យសេរីភាពក្នុងការចង់ចេះដឹងដោយខ្លួនឯង ដែលមានបង្កប់ធាតុសិក្សាសកម្មនៅក្នុងនោះទេ។ ផ្ទុយទៅវិញ ខ្លឹមសារមេរៀន និងសកម្មភាពក្នុងសៀវភៅសិក្សានោះ មានកំណត់ការរៀនបែបទន្ទេញចាំ និងបំណិនសញ្ញាណកម្មកម្រិតទាបទៅវិញ។ ហេតុផលនេះ កម្មវិធីអប់រំកម្រិតនេះ មិនបានជួយឱ្យសិស្សអាចបន្តការអប់រំកម្រិតខ្ពស់ទៀតបានស្រួលទេ ព្រោះថាការអប់រំកម្រិតឧត្តមសិក្សា ទាមទារឱ្យសិស្សចេះស្រាវជ្រាវ និងចេះឆ្លល់ និងស្វែងរកចម្លើយឯករាជ្យដោយខ្លួនឯង។ អ្នកសិក្សាតាមកម្មវិធីអប់រំនេះ មិនអាចក្លាយជាកម្លាំងពលកម្មប្រកបដោយភាពច្នៃប្រឌិត ឬ

តាមទាន់សភាពការណ៍បានទេ ព្រោះយើងត្រូវការធនធានមនុស្សខ្លាំងបែបនេះ ដើម្បីរុញសេដ្ឋកិច្ចកម្ពុជាទៅជាប្រទេសមានចំណូលមធ្យមត្រឹម កម្រិតខ្ពស់ត្រឹមឆ្នាំ ២០៣០។ ភាពខ្វះចន្លោះនៃកម្លាំងពលកម្មមានសម្ថភាពនេះ ក្នុងទីផ្សារ គឺមានអ្នកស្រាវជ្រាវបកស្រាយរួចមកហើយ (NEAa, ២០១៨)។ ការស្រាវជ្រាវនេះយកលើកឡើងថា និយោជកពិកបាករកនិយោជិកដែលមានជំនាញទន់ (រាប់តាំងពី ជំនាញទំនាក់ទំនង ការដោះស្រាយបញ្ហា និងជំនាញធ្វើការជាក្រុម) នេះមានន័យថា និយោជិតរបស់ខ្លួននៅខិនភាពសមត្ថភាពគន្លឹះ (NEAa, ២០១៨)។ ស្ថានភាពលំបាករកអ្នកត្រូវជំនាញបែបនេះ អាចនឹងកាន់តែអាក្រក់ជាងនេះ នៅពេលដែលសេដ្ឋកិច្ចប្រទេសឈានចូលសេដ្ឋកិច្ចពុទ្ធិកាន់តែច្រើនជាងមុន (ធនាគារពិភពលោក, ២០១៨)។

ក្រសួងអប់រំបានអនុវត្តក្របខណ្ឌកម្មវិធីសិក្សាថ្មី ក្នុងគោលបំណងបង្កើតឱ្យបានពលរដ្ឋ“ពេញលេញ”សម្រាប់ការអភិវឌ្ឍជាតិ(អ.យ.ក, ២០១៥)។ ដូច្នេះ ការរៀបចំសៀវភៅសិក្សាដែលជាផ្នែកដ៏សំខាន់នៃកម្មវិធីសិក្សាឡើងវិញ គឺជាអាទិភាពចម្រងដែលត្រូវធ្វើដើម្បីសម្រេចចក្ខុវិស័យសេដ្ឋកិច្ចពុទ្ធិនេះ។ ថ្វីបើថា កំណែទម្រង់លើការបង្រៀនខ្លឹមសារមេរៀន (ដូចជាវិធីសាស្រ្តណែនាំពីការរៀនមេរៀន និងការបណ្តុះបណ្តាលគ្រូ) ពិតជាមានសារៈសំខាន់ខ្លាំងក៏ដោយ ក៏ការកែលម្អខ្លឹមសារនៅតែជាការងារការស្នូលដដែល។ ប្រសិនបើ យើងមិនអាចកែប្រែសៀវភៅសិក្សាបានចប់សព្វគ្រប់ភ្លាមៗទេ យើងគួរតែប្រើប្រាស់ឯកសារសិក្សាបន្ថែមដែលពាក់ព័ន្ធនឹងពង្រឹងសកម្មសិនសិក្សាក៏បាន។ ឯកសារសិក្សាក្រៅពីនេះ យើងគួរតែស្វែងរកបន្ថែមឯកសារប្រភេទផ្សេងទៀត (ដូចជា សៀវភៅសិក្សា និងឯកសារបច្ចេកវិទ្យាព័ត៍មានវិទ្យា និងទំនាក់ទំនង) ដើម្បីបង្កើនការសិក្សាបែបរិះរក ព្រោះថាសៀវភៅសិក្សាបច្ចុប្បន្ន គឺមិនសូវមានបង្ហាញពីការសិក្សាបែបនេះទេ។ បើធ្វើដូចនេះមិនបានទេ នោះយើងនៅតែបន្តឱ្យមានភាពមិនស៊ីចង្វាក់គ្នារវាងអ្វីដែលគោលនយោបាយអប់រំជាតិចង់បាន និងសេដ្ឋកិច្ចពុទ្ធិដែលកម្ពុជាត្រូវការពិតប្រាកដ៕

## ឯកសារយោង


Anderson, L.W. & Krathwohl, D. (2001). A Taxonomy for Learning, Teaching, and Assessing: A Revision of Bloom's Taxonomy of Educational Objectives. New York: Longman.

Branch, J., & Oberg, D. (2004). Focus on Inquiry: A Teacher's Guide to Implanting Inquiry-Based Learning. Available at: http://education.alberta.ca/media/313361/focusoninquiry.pdf.

Chet, C., Ngin, C., Chhinh, S., Dy, S. & Ford, D. (2014). Reviews of Educational Contents, Pedagogies and Connectivity of Curriculum and its Relevance to Economic Development in Cambodia. Phnom Penh: Royal University of Phnom Penh and Capacity Development Partnership Fund.

Ministry of Education of Singapore (MoES). (2006). Mathematics Syllabus. Singapore: MoES.

Ministry of Education of Singapore (MoES). (2008). Arts Syllabus. Singapore: MoES.

Ministry of Education of Singapore (MoES). (2013). Science Syllabus. Singapore: MoES.

Ministry of Education, Youth and Sport (MoEYS). (1996). Core Curriculum for Primary Education, Lower-Secondary Education and Upper-Secondary Education: 1996-2005 (in Khmer). Phnom Penh: MoEYS.

Ministry of Education, Youth and Sport (MoEYS). (2001). Document for Teacher Orientation Training: Utilization of the New Curriculum and Textbook for Grade 6 (in Khmer). Phnom Penh: MoEYS.

Ministry of Education, Youth and Sport (MoEYS). (2004). Policy for Curriculum Development 2005-2009. Phnom Penh: MoEYS.

Ministry of Education, Youth and Sport (MoEYS). (2007). Child-friendly School Policy. Phnom Penh: MoEYS.

Ministry of Education, Youth and Sport (MoEYS). (2012). Policy and Guidelines for Core Textbook Development (in Khmer). Phnom Penh: MoEYS.

Ministry of Education, Youth and Sport (MoEYS). (2014). Education Strategic Plan: 2014-2018. Phnom Penh: MoEYS.

Ministry of Education, Youth and Sport (MoEYS). (2015). Curriculum Framework of General Education and Technical Education. Phnom Penh: MoEYS.

Nath, B. (1999). Teacher Training Systems in Cambodia. Discussion Paper. No. 78. Nagoya: Graduate School of International Development, Nagoya University.
National Employment Agency (NEAa) (2018). Cambodia Job Outlook 2018. Phnom Penh: NEA.
National Employment Agency (NEAb) (2018). Skills Shortages and Skills Gaps in the Cambodian Labour Market: Evidence from Employer Survey 2017. Phnom Penh: NEA.
Royal Government of Cambodia (RGC). (2013). Rectangular Strategy Phase III. Phnom Penh: RGC.
Royal Government of Cambodia (RGC). (2015). Cambodia Industrial Development Policy 2015-2025. Phnom Penh: RGC.
Wan, G & Morgan, P.J. (2017). Overview on 'Escaping the Middle-Income Trap'. *Journal of the Asia Pacific Economy*, 22:1, 1-4. DOI: 10.1080/13547860.2017.1263458.
Wilson, W.T. (2014). Beating the Middle-Income Trap in Southeast Asia. *Special Report No. 156*. Washington, DC: The Heritage Foundation.
World Bank. (2018). Cambodia Economic Update April 2018: Recent Economic Developments and Outlook. Phnom Penh: World Bank.
Yoshino, N., Morgan, P.J., Wan, G. & Huang, B. (2018). Avoiding the Middle-Income Trap in Asia: The Role of Trade, Manufacturing, and Finance. Tokyo: Asian Development Bank Institute.